# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់**
**និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**
**លេខ:០០៦/០៧ របក.គគចនយ**

## របាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ កុម្ភៈ ឆ្នាំ ២០០៧របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌និងទិសដៅសម្រាប់អនុវត្តបន្ត

ក្នុងខែ កុម្ភៈ ឆ្នាំ ២០០៧ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធមិ ដោយមាន អង្គភាព សម្របសម្រួលអចិន្ត្រៃយ៍ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមាន អង្គភាព គ្រប់គ្រងគម្រោង ជាអង្គភាពប្រតិបត្តិ បានដំណើរការងាររបស់ខ្លួនស្របតាមបេសកកម្ម ដែលបានកំណត់ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ហើយសម្រេចបាននូវលទ្ធផលជាក់ស្តែង ដូចខាងក្រោម ៖

**១-ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធមិ**

ក. ការងាររដ្ឋបាល

- រៀបចំលិខិតគាំទ្រសំណើររបស់វិទ្យាស្ថានគ្រប់គ្រងបូព៌ា-បស្ចឹម សុំពន្យាអនុស្សារណៈ នៃការយោគយល់គ្នាជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការ អន្តរជាតិ
- រៀបចំលិខិតអញ្ជើញចូលរួមប្រជុំក្រុមប្រតិបត្តិគម្រោង PEG នៅថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៧
- ទទួលដំណឹងអំពីការអនុម័តក្រមសីលធមិចៅក្រមដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

**ខ. ការងារកំណែទម្រង់**

- ប្រជុំមន្ត្រីអង្គភាពគ្រប់គ្រងគម្រោង ពង្រឹងការអនុវត្តការងារឆ្នាំថ្មី
- ចូលរួមប្រជុំ GDCC នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា CDC

- ប្រជុំក្រុមប្រតិបត្តិគម្រោង PEG ពិនិត្យអនុម័តគម្រោងថវិកាចំណាយឆ្នាំ ២០០៦ សម្រាប់ គម្រោងសិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា (A2J)
- ទទួលជួបជាមួយក្រុមការងារវាយតម្លៃគម្រោង CCJAP III/AusAid ដើម្បីការងារសហប្រតិបត្តិ ការទៅថ្ងៃមុខ
- ទទួលជួបជាមួយតំណាងអង្គការ DANIDA នៅកម្ពុជា ដើម្បីពង្រឹងការងារទំនាក់ទំនង
- ប្រជុំក្រុមការងារបច្ចេកទេសចម្រុះ (ទចេហានិចាល Working Group) នៅថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០៧
- ប្រជុំ PEG ដើម្បីអនុម័តរបាយការណ៍ ២០០៦ និងអនុម័តផែនការការងារ និងថវិកាប្រចាំឆ្នាំ ២០០៧
- ទទួលជួបក្រុមការងារ IFC ស្វែងយល់ពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ក្នុងវិស័យពាណិជ្ជកម្ម
- បញ្ចប់របាយការណ៍ស្តីពីលទ្ធផលនៃការអនុវត្តកម្មវិធីកំណែទម្រង់ច្បាប់ និងតុលាការ និងធ្វើការចែក ជូនទៅក្រសួង ស្ថាប័នពាក់ព័ន្ធ
- បំពេញ Annex I និង Annex II សម្រាប់ Project Document ពាក់ព័ន្ធនឹងសហប្រតិបត្តិការ រវាង PCB/PMU និង DIHR ។

គ. ផ្សេងៗ

- ចូលរួមសិក្ខាសាលាផ្សព្វផ្សាយឯកសារស្រាវជ្រាវរបស់វិទ្យាស្ថានអភិវឌ្ឍន៍សង្គម នៅសណ្ឋាគារ HIMAWARI
- ចូលរួមរៀបចំសន្និសីទស្តីពីអភិបាលកិច្ចលើកទី ២ ក្រោមអធិបតីភាពសម្តេចនាយករដ្ឋមន្ត្រី នៅថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៧ នៅសាលចតុមុខ ។

**២-សន្និដ្ឋាន**

ក្នុងខែ កុម្ភៈ ឆ្នាំ ២០០៦ នេះ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាព សម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាពគ្រប់គ្រងគម្រោងជាអង្គភាព ប្រតិបត្តិ បានខិតខំបំពេញការងារយ៉ាងសកម្ម ជាពិសេសបានចងក្រងគម្រោងលំអិត (Project Profile) និងបាន បញ្ចប់របាយការណ៍ប្រចាំឆ្នាំ ២០០៦ ព្រមទាំងបានអនុម័តផែនការថវិកាចំណាយសម្រាប់គម្រោង A2J ថែម ទៀត ។

៣-ទិសដៅអនុវត្តក្នុងខែបន្ត

- រៀបចំដំណើរការការងាររបស់អនុក្រុម (Sub-Group/TWG)

- រៀបចំសិក្ខាសាលាពិគ្រោះយោបល់លើការរៀបចំប្រព័ន្ធទិន្នន័យការយល់ដឹងសិទ្ធិមូលដ្ឋាន នៅ ថ្នាក់ សហគមន៍

-រៀបចំឯកសារសម្រាប់ការប្រជុំពាក់ព័ន្ធនឹងគម្រោងបង្កើតប្រព័ន្ធសូចនាករ សម្រាប់កំណែទម្រង់ច្បាប់ និងតុលាការទាំងមូល និងគម្រោងពង្រីកតុលាការគំរូ

- តាមដានភាពជឿនលឿនការអនុវត្តកំណែទម្រង់ច្បាប់ និងតុលាការ ។

*រាជធានី ភ្នំពេញ ថ្ងៃទី ខែ មីនា ឆ្នាំ ២០០៧*

អ្នកធ្វើរបាយការណ៍

ហ៊្សឹង សុកុល

បានឃើញ និងឯកភាព

នាយកអង្គភាពគ្រប់គ្រងគម្រោង

ស៊ុយ ម៉ុងលាង